ឆ្នាំ ទី ៦ លេខ ២២ សប្តាហ៍ ទី ៣ ថ្ងៃ ទី ២៣ ខែ មីនា ឆ្នាំ ២០០៦ រាជកិច្ច ទំព័រ ១៦២០

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ...២៩... អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅក្រុងព្រះសីហនុ សម្រាប់ការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ពង្រីកហេដ្ឋារចនាសម្ព័ន្ធដែលមានរួចហើយ ដើម្បីកសាងជាអាកាសយានដ្ឋានអន្តរជាតិ លំដាប់ថ្នាក់ 4E ស្របតាមស្តង់ដារអន្តរជាតិ ដែលអាចទទួលបានអាកាសយានគ្រប់ប្រភេទ ទាំងអាកាសយានដឹកអ្នកដំណើរ និង

អាកាសយានដឹកទំនិញ ដើម្បីអភិវឌ្ឍន៍ និងបង្កើនសកម្មភាពទេសចរណ៍· ឧស្សាហកម្ម ពាណិជ្ជកម្ម ជាពិសេស ឧស្សាហកម្ម ប្រេងឥន្ទៈ និងឧស្ម័ន នាអនាគត នៅតំបន់ក្រុងព្រះសីហនុដែលជាផលប្រយោជន៍សាធារណៈរបស់ជាតិ ។

**មាត្រា ២.~**

ធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ភ្ជាប់ជាឧបសម្ព័ន្ធ( ឧបសម្ព័ន្ធ ទី១) ដែលមានផ្ទៃក្រឡាសរុប ៦៨២ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅសង្កាត់រាម ខ័ណ្ឌព្រៃនុប ក្រុងព្រះសីហនុ ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥. ១៦. ១៧. នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ដើម្បីសម្រេចនូវគម្រោងនេះ និងមាននិយាមការ ដូចខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| (01) | 349698.2 E | 1171948.4 N | (21) | 351660.7 E | 1170416.8 N |
| (02) | 348926.5 E | 1170661.6 N | (22) | 351578.2 E | 1170481.3 N |
| (03) | 350128.5 E | 1169915.1 N | (23) | 350770.3 E | 1171111.2 N |
| (04) | 350352.0 E | 1169776.3 N | (24) | 351141.5 E | 1170714.3 N |
| (05) | 349885.5 E | 1168906.1 N | (25) | 350171.4 E | 1168854.6 N |
| (06) | 349419.0 E | 1168035.8 N | (26) | 349744.8 E | 1168058.7 N |
| (07) | 349033.9 E | 1167317.3 N | (27) | 350210.9 E | 1167808.8 N |
| (08) | 349686.5 E | 1166967.5 N | (28) | 350653.2 E | 1168613.8 N |
| (09) | 349926.7 E | 1167338.8 N | (29) | 349012.8 E | 1166988.1 N |
| (10) | 350194.2 E | 1167620.1 N | (30) | 349154.6 E | 1167252.5 N |
| (11) | 350337.4 E | 1167754.0 N | (31) | 349194.4 E | 1166890.7 N |
| (12) | 350547.9 E | 1167950.7 N | (32) | 349336.2 E | 1167155.2 N |
| (13) | 350747.8 E | 1168141.9 N | (33) | 348765.0 E | 1166815.3 N |
| (14) | 350906.3 E | 1168374.1 E | (34) | 348920.6 E | 1166308.2 N |
| (15) | 350986.3 E | 1168601.5 N | (35) | 349543.5 E | 1166307.9 N |
| (16) | 351044.7 E | 1169020.7 N | (36) | 349552.3 E | 1166716.9 N |
| (17) | 351162.0 E | 1169404.3 N | (37) | 351148.1 E | 1170971.3 N |
| (18) | 351288.8 E | 1169662.9 N | (38) | 351332.9 E | 1171316.1 N |
| (19) | 351351.9 E | 1169784.0 N | (39) | 351514.4 E | 1171218.8 N |
| (20) | 351634.6 E | 1170326.2 N | (40) | 351312.6 E | 1170842.2 N |

**មាត្រា ៣.~**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលឋិតក្នុងបរិវេណដីបង្កកដូចបាន ពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតអោយសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការ ផ្ទេរកម្មសិទ្ធិជាផលប្រយោជន៍របស់ជាតិ និងការបង្កបង្កើនផលកសិកម្មដែលបានទទួលការអនុញ្ញាតពីគណៈកម្មការ ចំពោះកិច្ច ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្ម ដែលមានចែង នៅមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ។

**មាត្រា ៤.~**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃឡូដី ក្នុងបរិវេណដែលនឹងត្រូវផ្ទេរកម្មសិទ្ធិ ឬភោគៈមកប្រគល់អោយរដ្ឋ នឹងទទួល បាននូវការទូរទាត់សំណង ក្រោមកិច្ចការអង្កេត និងការឯកភាពលើសំណើសំណង ស្នើឡើងដោយគណៈកម្មការចំពោះ កិច្ចមួយ ដែលជាសេនាធិការមានភារកិច្ចក្នុងការសម្របសម្រួល និងដោះស្រាយនូវរាល់បញ្ហាខាងលើនេះ ហើយ

គណៈកម្មការនេះ នឹងតែងតាំងដោយប្រកាស របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៥.-**

ជាមួយគ្នានេះដែរ ប្លង់ស្តីពីសេរីភាពសម្រាប់ការហោះហើរនៃអាកាសយាន នឹងត្រូវបញ្ចូលក្នុងរាល់ឯកសារនគរូបនីយកម្មនានា ដោយគោរពតាមលក្ខខ័ណ្ឌបច្ចេកទេស នៃ ការហោះហើរ ដូចមានចែងក្នុងឧបសម្ព័ន្ធ ទី២ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៧.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៦
- ឯកសារ - កាលប្បវត្តិ